# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៧...បប...

## បទបញ្ជា

## ស្តីពី

## ការទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យ នៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប

----------

កន្លងមក រាជរដ្ឋាភិបាលបានចេញសារាចរលេខ ០១ សរ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរ ដោយបានធ្វើការផ្សព្វផ្សាយ ដើម្បីធ្វើអោយសាធារណជន និងប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប និងចូលរួមអនុវត្តក្នុងកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌របស់ជាតិមាតុភូមិ. និងការថែរក្សារមណីយដ្ឋានអង្គរ ដែលជារមណីយដ្ឋានបេតិកភ័ណ្ឌពិភពលោក ។

នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី ១៣ គណៈកម្មការអន្តរជាតិសំរបសំរួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរកាលពីខែកុម្ភៈ ឆ្នាំ ២០០៤ នៅទីរួមខេត្តសៀមរាប ដោយមានតំណាងប្រទេសនានា និងអង្គការអន្តរជាតិចូលរួមរាប់រយនាក់នោះ បានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាយើង ក៏ដូចអាជ្ញាធរអប្សរា អាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធដែលបានខិតខំអនុវត្តការងារក្នុងរយៈពេលកន្លងមក ធ្វើអោយរមណីយដ្ឋានអង្គរឈានផុតពីរមណីយដ្ឋានដែលប្រឈមមុខនឹងគ្រោះថ្នាក់ ហើយក្លាយជារមណីយដ្ឋានដែលកំពុងតែអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសបានខិតខំអនុវត្តតាមស្មារតីសារាចរលេខ ០១ សរ ស្តីពីការទប់ស្កាត់អំពើ អនាធិបតេយ្យនៅតំបន់សៀមរាប-អង្គរនេះ ។

ចាប់ពីពេលនេះតទៅ ភារកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការយូណេស្កូ និងសហគមន៍អន្តរជាតិ ត្រូវធ្វើការរួមគ្នា ដើម្បីធានាអោយបាននូវការងារអភិរក្សរមណីយដ្ឋានអង្គរ ដោយដើរស្របគ្នាជាមួយនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំដៅបំរើវិស័យឧស្សាហកម្មទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ក្នុងផ្នែកអភិរក្ស អាទិភាពត្រូវផ្តល់អោយដល់ការថែទាំ ការពាររមណីយដ្ឋានអង្គរដែលស្ថិតនៅក្នុងតំបន់. ១ ដែលជា " រមណីយដ្ឋានមានប្រាសាទ " និងតំបន់ ២ ដែលជា " ឧទ្យានបុរាណវត្ថុត្រូវការពារ " មានទំហំប្រមាណ ៤០១គីឡូម៉ែត្រការេ ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប ហើយអាចពង្រីកទំហំថែមទៀត និងមានការបែងចែកជា ៥ តំបន់ ដែលត្រូវមានកំរិតការពារលក្ខខណ្ឌប្រើប្រាស់ដីធ្លី និងការសាងសង់សំណង់ខុសៗគ្នា ។

ប៉ុន្តែទន្ទឹមនឹងមោទនភាពខាងលើ និងក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ សកម្មភាពកាប់រានដុតបំផ្លាញព្រៃឈើ ឈូសឆាយចាក់ដី ជីកយកដី ហ៊ុមព័ទ្ធរបងយកដី សាងសង់លំនៅដ្ឋានដែលមានលក្ខណៈរឹងមាំអំពីបេតុង សាងសង់សំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា ដាក់លក់វត្ថុអនុស្សាវរីយ៍ អាហារ និងភេសជ្ជៈ ប្រេងឥន្ធនៈ ការចតយានយន្ត មធ្យោបាយដឹកភ្ញៀវទេសចរគ្មានសណ្តាប់ធ្នាប់ និងគ្មានការអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរា ព្រមទាំងការលែងគោ ក្របី ជ្រូក អោយដើរពាសវាលពាសកាលបានកើនឡើងជាបន្តបន្ទាប់ឥតឈប់ឈរនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប ។

អំពើល្មើសទាំងនេះ បានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍នីតិរដ្ឋ និងដល់គោលការណ៍អភិវឌ្ឍប្រកបដោយនិរន្តរភាព បើសិនជាវិធានការទប់ស្កាត់ និងលុបបំបាត់ ពុំត្រូវចាត់ការអនុវត្តអោយបានហ្មឹងម៉ាត់ និងមានប្រសិទ្ធភាពនោះទេ ។

ដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យនៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវបទបញ្ជាបន្ទាន់ចំពោះមុខ ដូចខាងក្រោម :

១. ដោយហេតុថា តំបន់រមណីយដ្ឋានអង្គរជាបេតិកភ័ណ្ឌពិភពលោក អាជ្ញាធរអប្សរាត្រូវទទួលភារកិច្ចផ្តាច់មុខជាអ្នកចាត់ចែងពិធីគ្រប់ជំពូកទាំងអស់ក្នុងបរិវេណអង្គរ ។

អាជ្ញាធរអប្សរាជាស្ថាប័នមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់សំរាប់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានអង្គរ ។ ការអនុញ្ញាតសាងសង់ ដែលចេញដោយអាជ្ញាធរផ្សេងពីអាជ្ញាធរអប្សរា ទាក់ទងនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានអង្គរត្រូវចាត់ទុកជាមោឃៈ ។ សំណង់កសាងរួចហើយ ដែលគ្មានច្បាប់អនុញ្ញាតអាចត្រូវរុះរើចេញដោយម្ចាស់សំណង់ល្មើសច្បាប់ ហើយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ថ្ងៃ យ៉ាងយូរគិតពីថ្ងៃជូនដំណឹង ។

ការស្ថាបនាសំណង់សាធារណៈរបស់រដ្ឋ ដែលមានសារៈសំខាន់ចាំបាច់នៅក្នុងតំបន់ ១ និងតំបន់ ២ នៃ រមណីយដ្ឋានអង្គរ ត្រូវមានយោបល់ជាមុនលើផ្នែកបច្ចេកទេសពីអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

ចំពោះសំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា លំនៅដ្ឋានថ្មីៗ តូបលក់ដូរទំនិញគ្រប់ប្រភេទ ចំណតយានយន្ត មធ្យោបាយដឹកភ្ញៀវទេសចរ ការព័ទ្ធរបងយកដី ការដ្ឋានឈូសឆាយចាក់ដី ជីកដី ឡឥដ្ឋ ឡធ្យូង ការកាប់ឈើទន្ទ្រានយកដី និងការចោះដើមឈើដុតយកជ័រដោយអនាធិបតេយ្យ ដែលបាន ឬកំពុងសាងសង់ និងដំណើរការនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាត្រូវសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់ការអនុវត្តជាបន្ទាន់បំផុតនូវការចុះស្រង់ស្ថិតិឈ្មោះជនល្មើស និងទីតាំងនីមួយៗអោយបានច្បាស់លាស់ រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន និងត្រូវធ្វើការទប់ស្កាត់មិនអោយអំពើអនាធិបតេយ្យរបៀបនេះ កើតឡើងជាថ្មីនៅតំបន់ទាំងពីរនេះតទៅទៀតឡើយ ។

ចំពោះការដ្ឋានដែលជនល្មើសបានកាប់រានដីព្រៃឈើ ព័ទ្ធរបងយកដីនៅក្នុងរមណីយដ្ឋានអង្គរ ក្រោយពេលអនុវត្តរឹបអូសយកមកធ្វើជាសម្បត្តិរដ្ឋតាមនីតិវិធីជាធរមានរួចហើយនោះ ត្រូវធ្វើការដាំដើមឈើឡើងវិញ និងចាត់ចែងការពារអោយបានហ្មឹងម៉ាត់ ។

២. រាល់ការលក់ដូរ ដោះដូរ ឬសម្បទានអ្វីមួយនៅលើដីធ្លីស្ថិតនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ ត្រូវចាត់ទុកជាមោឃៈ ។ ចំពោះរាល់ការចេញលិខិត ឬប័ណ្ណសំគាល់សិទ្ធិដីធ្លីដែលស្ថិតនៅក្នុងតំបន់ទាំងពីរនេះជូនប្រជាពលរដ្ឋដែលតាំងទីលំនៅ និងរស់នៅយូរលង់មកហើយ ត្រូវមានយោបល់ឯកភាពពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរាជាមុន ។

៣. រាល់វិធានការ និងការអនុញ្ញាតទាំងឡាយណាដែលចេញដោយអាជ្ញាធរជាតិ ឬអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលមានវិសមិតភាពជាមួយកាតព្វកិច្ចអន្តរជាតិ ដែលតម្រូវអោយព្រះរាជាណាចក្រកម្ពុជាគោរព និងអនុវត្តនៅក្នុងរមណីយដ្ឋានអង្គរ ត្រូវចាត់ទុកជានិរាករណ៍ ។ ហេតុនេះ ការដាក់តម្លើងអង់តែន ទូរស័ព្ទ ទូរទស្សន៍ និងសំណង់ទាំងអស់ដែលគ្មានច្បាប់កន្លងមក ហើយដែលស្ថិតនៅក្នុងតំបន់ ១ និងតំបន់ការពារផ្សេងៗទៀត នៃរមណីយដ្ឋានអង្គរ ត្រូវតែរុះរើចេញដោយគ្មានលក្ខខណ្ឌ ហើយចាប់ពីពេលនេះតទៅ ហាមឃាត់ដាច់ខាតការតម្លើងអង់តែន ឬសំណង់ផ្សេងៗក្នុងតំបន់១ និងតំបន់ការពារផ្សេងៗដូចខាងលើ លើកលែងតែមានការអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរា និងមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

៤. លើកកំពស់ការអនុវត្ត តាមគោលការណ៍នីតិរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប គឺអាជ្ញាធរអប្សរាត្រូវខិតខំកសាងលិខិតបទដ្ឋានបន្ថែមទៀត បន្តបោះបង្គោលកំណត់ខ័ណ្ឌព្រំដីជាក់ស្តែងនៅតាមតំបន់ទាំង ៥ ការដាក់ផ្លាកសញ្ញាបង្ហាញ ការជូនដំណឹងនានាអំពីសិទ្ធិប្រើប្រាស់ដីធ្លី និងកំរិតលក្ខខណ្ឌនៃការសាងសង់សំណង់ ហើយធ្វើការផ្សព្វផ្សាយជាប់ជាប្រចាំ និងការជំរុញស្មារតីចូលរួមអនុវត្តច្បាប់ បទបញ្ជា បទប្បញ្ញត្តិ និងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធជាមួយនឹងតំបន់រមណីយដ្ឋានអង្គរ កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ការការពារព្រៃឈើ និងសត្វព្រៃជាដើម ជូនកងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ សិស្សានុសិស្ស ព្រះសង្ឃ សាធារណជន និងប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ដោយសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានសិក្សា វត្តអារាម ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ។

៥. អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ត្រូវខិតខំជំរុញដំណើរការរៀបចំ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយ ធានារក្សានូវសោភ័ណភាពប្រាសាទបុរាណសំរាប់បំរើការទស្សនារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរនូវតូបលក់វត្ថុអនុស្សាវរីយ៍ អាហារ និងភេសជ្ជៈ ផ្លូវថ្មើរជើង ចំណតយានយន្ត និងមធ្យោបាយដឹកជញ្ជូនភ្ញៀវ ទេសចរ ដោយហាមឃាត់ដាច់ខាតមិនអោយមានការលក់ដូរប្រេងឥន្ធនៈ និងគ្រឿងឆេះផ្សេងៗ ព្រមទាំងមិនអោយលែងគោ ក្របី ជ្រូក ពាសវាលពាសកាលឡើយ ។

៦. គ្មានរូបវន្តបុគ្គល នីតិបុគ្គល សមាគម អង្គការ ឬអាជ្ញាធរណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី អោយកាប់រានដី ដុតឈូសឆាយព្រៃឈើ ចាក់ដី ជីកដី បង្កើតឡឥដ្ឋ ឡធ្យូង ហ៊ុមព័ទ្ធរបងយកដី សាងសង់សំណង់សាធារណៈរបស់រដ្ឋ សំណង់សាសនា លំនៅដ្ឋាន តូបលក់ដូរទំនិញគ្រប់ប្រភេទ ឬការចាត់ចែងរៀបចំចំណតយានយន្ត និងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរនៅក្នុងតំបន់ ១ និងតំបន់ ២ នៃរមណីយដ្ឋានអង្គរ ក្រៅពីសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរាឡើយ ។

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ត្រូវរៀបចំទីស្នាក់ការធ្វើការរួមមួយជាបន្ទាន់ ដែលម្យ៉ាងសំរាប់អោយថ្នាក់ដឹកនាំអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងមន្ត្រីរាជការ បុគ្គលិកបំរើការងារផង និងម្យ៉ាងទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់ វិនិយោគិន សាធារណជន ប្រជាពលរដ្ឋ ស្ថាប័ន អង្គភាពមានសមត្ថកិច្ច អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងតំណាងប្រទេសនានាធ្វើការទាក់ទងការងារ ព្រមទាំងត្រូវកំណត់អំពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតតាមច្រកចេញ ចូលតែមួយ រយៈពេលនៃការដាក់ពាក្យស្នើសុំរុះរើ កែលំអ សាងសង់លំនៅដ្ឋាន ការវិនិយោគ និងកិច្ចការទំនាក់ទំនងសាធារណៈផ្សេងៗទៀតជាដើម ដែលពាក់ព័ន្ធនឹងការងារអភិរក្ស និងអភិវឌ្ឍនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ។

៧. ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ជាខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល ច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

៨. ទទួលបាននូវបទបញ្ជានេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់នៃខេត្តសៀមរាប និងខេត្ត ក្រុងពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយអោយបានទូលំទូលាយ និងចាត់ចែងអនុវត្តអោយមានប្រសិទ្ធភាព ដោយទទួលលទ្ធផលជាវិជ្ជមាន ។ Ru

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ